ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ១៧១៦ គ.ជ.ប

# សេចក្តីណែនាំ
## ស្តីពី
## កិច្ចសហការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ សម្រាប់ការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧

- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- ផ្អែកតាមអនុក្រឹត្យលេខ ១២៦.អនក្រ.បកចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការពារការចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ ។
- ផ្អែកតាមផែនការអន្តរស្ថាប័នលេខ ០០៩ ផ.ក/១៦ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ស្តីពីកិច្ចការពារការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ ។

ក្នុងគោលបំណងឱ្យដំណើរការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧ ប្រព្រឹត្តទៅដោយរលូនល្អ ក្នុងបរិយាកាសសន្តិសុខ សុវត្ថិភាព គ្មានការបំភិតបំភ័យ គ្មានការគំរាមកំហែង និងគ្មានអំពើហិង្សា **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)** សូមណែនាំដល់លោក លោកស្រី ប្រធានលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) អនុវត្តការងារមួយចំនួនដូចតទៅ៖

- ត្រូវទាក់ទង និងសហការជាមួយអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ដែលជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ដើម្បីចាត់វិធានការការពារសន្តិសុខ និងស្នើសុំរៀបចំកម្លាំងនគរបាល ឬ/និងកម្លាំងកងរាជអាវុធហត្ថ ដែលមានមូលដ្ឋានឈរជើងក្នុងរាជធានី ខេត្តនីមួយៗ ការពារការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧ ដោយផ្អែកតាមផែនការអន្តរស្ថាប័នលេខ ០០៩ ផក/១៦ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និង គ.ជ.ប ស្តីពីកិច្ចការពារការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦ដល់ឆ្នាំ២០១៩។

- ត្រូវពង្រឹងកិច្ចសហការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ នៅគ្រប់ការិយាល័យចុះឈ្មោះបោះឆ្នោត ដែលមានទីតាំងនៅសាលាឃុំ សង្កាត់ និងទីតាំងមួយចំនួនទៀតតាមភូមិក្នុងឃុំ សង្កាត់ នៃរាជធានី ខេត្តនីមួយៗ។

- ត្រូវចាត់ចែង តាមដាន ត្រួតពិនិត្យសភាពការណ៍ និងស្នើសុំអន្តរាគមន៍ពីកម្លាំងមានសមត្ថកិច្ច ក្នុងករណីមានការអុកឡុករំខាន ការគំរាមកំហែង អំពើល្មើសផ្សេងៗទៀត ដែលធ្វើឱ្យរាំងស្ទះដល់ដំណើរការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧។

- ត្រូវផ្តល់ព័ត៌មាន និងរបាយការណ៍ជាប្រចាំអំពីស្ថានភាពសន្តិសុខ សុវត្ថិភាព ជុំវិញដំណើរការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧ ជូន គ.ជ.ប ឱ្យបានទៀងទាត់។ ក្នុងករណីចាំបាច់ ត្រូវរាយការណ៍ជាបន្ទាន់ជូនលេខាធិការដ្ឋានសន្តិសុខបោះឆ្នោត នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប ដើម្បីមានវិធានការដោះស្រាយឱ្យបានទាន់ពេលវេលា។

ដើម្បីបង្ការ ទប់ស្កាត់ និងកាត់បន្ថយនូវបាតុភាពនានា ដែលអាចកើតមានជាយថាហេតុ ក្នុងដំណើរការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧ នេះ លោក លោកស្រី ប្រធាន លធ.ឧប ត្រូវចាត់ចែងរៀបចំនូវកិច្ចប្រជុំឱ្យបានទៀងទាត់ក្នុង ២ សប្តាហ៍ម្តង។

សមាសភាពដែលចូលរួមក្នុងកិច្ចប្រជុំនេះ រួមមាន ៖

- ប្រធាន លធ.ឧប ជាប្រធានអង្គប្រជុំ
- អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ឬតំណាង
- ស្នងការនគរបាលរាជធានី ខេត្ត ឬតំណាង
- មេបញ្ជាការប្រតិបត្តិការសឹករងរាជធានី ខេត្ត ឬតំណាង
- មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ខេត្ត ឬតំណាង
- តំណាងគណបក្សនយោបាយប្រចាំរាជធានី ខេត្ត
- តំណាងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធប្រចាំរាជធានី ខេត្ត
- អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ។

ទទួលបានសេចក្តីណែនាំនេះ សូមលោក លោកស្រី ប្រធាន លធ.ឧប ទាំងអស់ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៧

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

សុិក ប៊ុនហុក

**ចម្លងជូន**

- ខុទ្ទកាល័យសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី
- គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត ( គ.ស.អ)
- លេខាធិការដ្ឋាន នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍
- អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ